

**ឯកឧត្តម** : **អ៊ុំ ស៊ឹម**

គណបក្ស : ហ៊្វុនស៊ិនប៉ិច

ថ្ងៃ ខែ ឆ្នាំកំណើត : ០៧ មករា ១៩៥០

ទីកន្លែងកំណើត : ភូមិសង្កែដុក ឃុំវល្លិសរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

ព័ត៌មានគ្រួសារ :

-ចំនួនកូន : ០៥នាក់ ប្រុស០៤នាក់ ស្រី១នាក់

កម្រិតវប្បធម៌ទូទៅ: -ថ្នាក់ទី៦ចាស់

កម្រិតបណ្តុះបណ្តាលមុខវិជ្ជាជីវៈ : -វិជ្ជាពេទ្យ និងនាយទាហាន (អនុសេនីយ៍ឯក)

ភាសាបរទេស : -ភាសាបារាំង

តំណែងក្នុងព្រឹទ្ធសភានីតិកាលទី១: សមាជិកព្រឹទ្ធសភា

ធ្លាប់ជាប់ជាសមាជិកព្រឹទ្ធសភាចំនួន: ១នីតិកាល

ប្រវត្តិការងារ

-១៩៩២ :វិជ្ជាពេទ្យនាយទាហាន (អនុសេនីយ៍ឯក) រៀនវគ្គឃោសនិក លើកទី១ ត្រុំ-ស្រុកអំពិល ខេត្តឧត្តរមានជ័យ បន្ទាប់មកជាប្រធានយុទ្ធនាការឃោសនាបោះឆ្នោតទូទាំងខេត្តកំពង់ស្ពឺ។

-១៩៩២/១៩៩៣ :ជាអនុប្រធានគណបក្សហ៊្វុនស៊ិនប៉ិចខេត្ត ជាអភិបាលរងទី២ ខេត្តកំពង់ស្ពឺ ហើយបានចូលបំប៉នវគ្គសុក្រិតការមន្ត្រីជាន់ខ្ពស់ ឯកទេសរដ្ឋបាលទូទៅ នៅសាលាភូមិន្ទរដ្ឋបាល (ERA) ភ្នំពេញ។ ហើយក៏ជាសមាជិកក្រុមប្រឹក្សាជាតិលើកទី១ អត្តលេខ១៣១។

-ក្រោយថ្ងៃ៥-៦ កក្កដា ១៩៩៧ បានទទួលការតែងតាំងជាអ្នកជំនួយការរបស់ ឯកឧត្តម ទេព ននី បេសកកម្មជន

ពិសេសសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជនភៀសខ្លួនខ្មែរ និងកងទ័ព អ្នកតស៊ូតាមជាយដែន (ព្រំដែនខ្មែរ-ថៃ)។

-១៩៩៨ បានទទួលការតែងតាំងជាប្រធានគណៈកម្មាធិការប្រតិបត្តិគណបក្សហ៊្វុនស៊ិនប៉ិចប្រចាំខេត្តកំពង់ស្ពឺ និងបានទទួលនូវតួនាទីមួយផ្សេងទៀត គឺតំណាងរាស្ត្រពេញសិទ្ធិក្នុងអណត្តិទី២។

អាសយដ្ឋានបច្ចុប្បន្ន: ភូមិរំលោង ឃុំសុពណ៌ទេព ស្រុកបា្សរមន ខេត្តកំពង់ស្ពឺ